**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ :.......០០១/១៨..............ក.ប/ស.ជ.ណ.ម.ក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចុះបញ្ជីទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយស សូមជូនដំណឹងដល់សាធារណៈជនទាំងអស់ឱ្យបានជ្រាបថា ក្នុងការរួមចំណែកដំណើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ ដែលបានកំណត់ឱ្យបង្កើតទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុកក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពសេវាការងារ និងពង្រីកវិសាលភាពនៃអភិបាលកិច្ចទីផ្សារការងារ ក្រសួង បានចេញប្រកាសលេខ៤៦៣ កប/ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីទីភ្នាក់ងារឯកជនផ្តល់ សេវារកការងារឱ្យធ្វើក្នុងស្រុក។

កន្លងមក ក្រសួងបានសង្កេតឃើញថា មានក្រុមហ៊ុន និងបុគ្គលឯកជនមួយចំនួន បាននឹងកំពុងដំណើរការផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក ដោយពុំទាន់បានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យស្របទៅតាមបទប្បញ្ញតិនៃប្រកាសលេខ៤៦៣កប/ប្រកស្តីពីទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុកនៅឡើយ។

ដូច្នេះដើម្បីអនុវត្តតាមបទប្បញ្ញតិនៃប្រកាសនេះ ក្រុមហ៊ុន ឬនីតិបុគ្គលដែលបាននិងកំពុងដំណើរការផ្តល់សេវារកការងារឱ្យធ្វើ និងនីតិបុគ្គលឯកជនដែលមានបំណងធ្វើជាទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក ត្រូវបំពេញបែបបទស្នើសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមុនទើបអាចដំណើរការបានស្របតាមនីតិវិធីច្បាប់។

ការអនុវត្តទាំងឡាយណាដែលមិនអនុលោមទៅតាមការណែនាំខាងលើ និងមិនស្របតាម ប្រកាសលេខ ៤៦៣ កប/ប្រក ស្តីពីទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក នឹងត្រូវទទួលការដាក់ពិន័យទៅតាមបទប្បញ្ញត្តិជាធរមាន។

សម្រាប់ព័ត៌មានបន្ថែម សូមធ្វើការទាក់ទងជាមួយការិយាល័យរកការងារឱ្យធ្វើក្នុងស្រុក នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមអាសយដ្ឋានខាងលើ ឬទូរស័ព្ទលេខ ០១២ ៩៣៩ ៤១៧ និងលេខ ០១៦ ៥២២ ៥០០ ឬតាមរយៈ Email: dem.ploffice@gmail.com ចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងនេះតទៅ។

អាស្រ័យហេតុនេះ សូមសាធារណៈជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ៨រោច ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

*-ខុទ្ទការល័យឯកឧត្តមរដ្ឋមន្ត្រី*

*"ដើម្បីជូនជ្រាប"*

*-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត-ក្រុង*

*"ដើម្បីអនុវត្ត"*

*ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ :........................................ក.ប**

## ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យក្រុមហ៊ុន.......................................................
## ធ្វើជាទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់នឹងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញគោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ខែកញ្ញាឆ្នាំ២០១៥
- បានឃើញប្រកាសលេខ៤៦៣បក/ប្រកចុះថ្ងៃទី២៨ខែតុលាឆ្នាំ២០១៦ស្តីពីទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក
- តាមសំណើរបស់ក្រុមហ៊ុន..............................................................ចុះថ្ងៃទី...........ខែ..................ឆ្នាំ២០១....
- យោងតាមកិច្ចសន្យាស្តីពីការផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុករបស់.....................................................................ចុះថ្ងៃទី..............ខែ..................ឆ្នាំ២០១......

## សម្រេច

**ប្រការ១**.-

ត្រូវបានអនុញ្ញាតឱ្យក្រុមហ៊ុន..............................................................................................
តំណាងដោយលោក/លោកស្រី..........................................ជនជាតិ.....................សញ្ជាតិ.....................
អាយុ................កាន់អត្តសញ្ញាណប័ណ្ណលេខ........................................ចុះថ្ងៃទី...................................
អាសយដ្ឋានបច្ចុប្បន្ន....................................................................................................................
បង្កើតទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក ដូចខាងក្រោម៖

-នាមករណ៍.......................................................................................................................................
-ទីតាំងភ្នាក់ងារ ...........................................................................................................................
-លេខចុះបញ្ជីទីភ្នាក់ងារ ...............................................................................................................

**ប្រការ២.-**

..........................................................................................................................................ត្រូវ៖

-ធ្វើរបាយការណ៍តាមការកំណត់របស់ក្រសួង

-អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ ប្រកាស កិច្ចសន្យា លិខិតបទដ្ឋានគតិយុត្តនិងបទបញ្ជាជាធរមាន។

**ប្រការ៣.-**

ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុកត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងករណីប្រព្រឹត្ត ផ្ទុយពីប្រកាសលេខ៤៦៣កប/ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីទីភ្នាក់ងារឯកជនផ្តល់សេវារកការងារ ឱ្យធ្វើក្នុងស្រុក បទប្បញ្ញត្តិនៃច្បាប់ និងបទបញ្ជានានាជាធរមាន។

**ប្រការ៤.-**

ប្រកាសនេះមានសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា។ សំណើសុំបន្តសុពលភាព ប្រកាសអនុញ្ញាតនេះ ត្រូវបញ្ជូនមកក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបាន៣០(សាមសិប)ថ្ងៃ មុន កាលបរិច្ឆេទដែលប្រកាសនេះអស់សុពលភាព។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ប្រធានក្រុមហ៊ុន និងគ្រប់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

***កន្លែងទទួល៖***

*-ទីស្តីការគណៈរដ្ឋមន្ត្រី*

*-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ*

*"ដើម្បីជូនជ្រាប"*

*-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត-ក្រុង*

*"ដើម្បីអនុវត្ត"*

*-ដូចប្រការ៥*

*ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ..............................កប**

# វិញ្ញាបនបត្រ
# បញ្ជាក់ការអនុញ្ញាតឲ្យដំណើរការ

រូបថត

៤X៦

នាមករណ៍ : ..........................................................................

ឈ្មោះម្ចាស់ក្រុមហ៊ុន : ..........................................................................

ត្រូវបានទទួលស្គាល់ជា : ..........................................................................

ទីតាំង : ..........................................................................

លេខចុះបញ្ជីទីភ្នាក់ងារ : ...............................ចុះថ្ងៃទី...............ខែ.....................ឆ្នាំ.......................................

ស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងប្រកាសលេខ៨៦៣ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១៦។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ គ.ស ២០១៨

**រដ្ឋមន្ត្រី**

* វិញ្ញាបនបត្រនេះមានសុពលភាពត្រឹមថ្ងៃ.........ខែ..........ឆ្នាំ............

* វិញ្ញាបនបត្រនេះត្រូវមកប្តូរជាថ្មីក្នុងរយៈពេល៣០ថ្ងៃ មុនថ្ងៃផុតកំណត់

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា  ព្រះមហាក្សត្រ

# កិច្ចសន្យា
# ស្តីពី
# ការផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................................អាយុ..........ឆ្នាំ ជនជាតិ.....................
សញ្ជាតិ......................មុខរបរ...............................................កាន់អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន
លេខ.......................................ជាម្ចាស់/ប្រធានក្រុមហ៊ុន..........................................................
ដែលមានទីតាំងស្ថិតនៅផ្ទះលេខ.............ផ្លូវលេខ...............ក្រុម..........ភូមិ........................................
ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ..............................ខេត្ត/រាជធានី........................................
ដែលក្នុងកិច្ចសន្យានេះហៅថា "ក្រុមហ៊ុន" ក្នុងការផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកជូនពលរដ្ឋខ្មែរ សូមសន្យាចំពោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចតទៅ៖

**ប្រការ១**.-

ក្រុមហ៊ុនសន្យាថានឹងអនុវត្តតាមច្បាប់ ប្រកាស លិខិតបទដ្ឋាន និងបទបញ្ជានានាជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២**.-

ក្នុងសកម្មភាពទាំងឡាយនៃការផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក ក្រុមហ៊ុនសន្យាថានឹងអនុវត្តតាមបទប្បញ្ញត្តិជាធរមាន ដោយមិនមានការរំលោភបំពានសិទ្ធិ ការកេងប្រវ័ញ្ច និងការជួញដូរមនុស្ស។

**ប្រការ៣**.-

ក្រុមហ៊ុនសន្យាថានឹងរៀបចំឱ្យមានទីតាំងសមស្រប សម្រាប់ដំណើរការប្រឹក្សាយោបល់ ការបង្ហាត់បង្ហាញ និងការណែនាំតម្រង់ទិសអំពីការងារ។

**ប្រការ៤**.-

ក្រុមហ៊ុនសន្យាថានឹងអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃប្រកាសលេខ ៤៦៣កប/ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក។

**ប្រការ៥**.-

ក្នុងករណីមានវិវាទកើតឡើងរវាងអ្នកស្វែងរកការងារធ្វើ និងក្រុមហ៊ុន ក្រុមហ៊ុនសន្យាថានឹងខិតខំដោះស្រាយដោយសន្តិវិធី ដោយឈរលើការសម្របសម្រួល ឬតាមច្បាប់ និងបទបញ្ជាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៦**.-

ក្នុងការផ្សព្វផ្សាយជូនដំណឹងអំពីការជ្រើសរើសកំលាំងពលកម្ម ការបណ្តុះបណ្តាលណែនាំតម្រង់ទិសការងារ និងការដាក់ឲ្យធ្វើការងារ ក្រុមហ៊ុនសន្យាថា នឹងអនុវត្តឲ្យបានត្រឹមត្រូវតាមការកំណត់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសហការឲ្យបានល្អជាមួយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៧.-**

ក្រុមហ៊ុនសន្យាថានឹងផ្តល់របាយការណ៍អំពីសកម្មភាពនៃការផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុកទៅតាមការកំណត់របស់ក្រសួង។

**ប្រការ៨.-**

ក្នុងករណីក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ មិនគោរពតាមច្បាប់ បទបញ្ញានានា និងការកំណត់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬអនុវត្តផ្ទុយពីកិច្ចសន្យានេះ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**ប្រការ៩.-**

កិច្ចសន្យានេះ ធ្វើឡើងជាភាសាខ្មែរ ចំនួន០២ច្បាប់។

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**ម្ចាស់/នាយកក្រុមហ៊ុន**...................

**បានឃើញ**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ:..............................ក.ប

ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨